**សេចក្តីប្រកាសព័ត៌មាន**

**នៅវ៉ាស៊ីនតោន ឌីស៊ី ៖**

ណាឌីន ហ្គាណាម (Nadine Ghannam)

លេខទូរស័ព្ទៈ +១ (២០២) ៤៧៣-៣០១១

អ៊ីម៉ែលៈ nsghannam@ifc.org

**នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក**

ហេនហ្វ្រិត វ៉ុន ហ៊ីនដេនប៊ឹក (Hannfried von Hindenburg)

លេខទូរស័ព្ទៈ +១ (២០២) ៤៦០-៧៧១៧

អ៊ីម៉ែលៈ hvonhindenburg@ifc.org

# ***ការធ្វើអាជីវកម្មឆ្នាំ២០១០:*** កំណត់ត្រាប្រចាំឆ្នាំអំពីកំណែទំរង់បទបញ្ញត្តិ — កម្ពុជានៅមានចន្លោះក្នុងការកែលំអបរិយាកាសអាជីវកម្ម

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ —** ប្រទេសកម្ពុជានៅតែស្ថិតក្នុងលំដាប់ថ្នាក់ទាបនៅក្នុងចំណាត់ថ្នាក់លើការសំរួលដល់ការធ្វើអាជីវកម្មពិភពលោក ក្នុងឆ្នាំ ២០០៨/២០០៩ ខណៈដែលសេដ្ឋកិច្ចភាគច្រើននៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានពង្រឹងបទបញ្ញត្តិអាជីវកម្មរបស់ខ្លួន ដើម្បីបង្កើនកាលានុវត្តភាពសំរាប់ក្រុមហ៊ុនក្នុងស្រុក។ សេដ្ឋកិច្ចនៃប្រទេសចំនួនបី នៅក្នុងតំបន់ - រាប់តាមលំដាប់គឺ ប្រទេស សឹង្ហបុរី ណូវែលហ្សេឡង់ និងហុងកុង (ចិន) -គឺជាអ្នកនាំមុខគេ នៅក្នុងការសំរួលដល់ការធ្វើអាជីវកម្ម។

យោងតាមរបាយការណ៍ *ការធ្វើអាជីវកម្មឆ្នាំ២០១០: កំណែទំរង់ក្នុងពេលលំបាក* ដែលជារបាយការណ៍ទីប្រាំពីរនៃរបាយការណ៍ប្រចាំឆ្នាំ ចេញផ្សាយដោយ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងធនាគារពិភពលោក នៅចន្លោះខែមិថុនា ឆ្នាំ២០០៨ ដល់ ខែឧសភា ឆ្នាំ២០០៩ ប្រទេសចំនួន១៣១ ក្នុងចំណោមប្រទេសទាំង ១៨៣

នៅទូទាំងពិភពលោក បានកែទំរង់បទបញ្ញត្តិអាជីវកម្មរបស់ខ្លួន ។ នៅក្នុងតំបន់អាស៊ីបូពា និង ប៉ាស៊ីហ្វិក ប្រទេសចំនួន ១៧ ក្នុងចំណោមប្រទេសទាំង២៤ បានធ្វើកំណែទំរង់ក្នុងពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោក ។

ប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់ទី ១៤៥ ក្នុងចំណោមប្រទេស ១៨៣ លើការសំរួលដល់ការធ្វើអាជីវកម្ម ។ ការផ្តល់ចំណាត់ថ្នាក់នេះកើតចេញពីវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលជំរុញឱ្យប្រទេសជាច្រើនបង្កើនល្បឿនកំណែទំរង់របស់គេ ហើយធ្វើឱ្យពួកគេទទួលបានចំណាត់ថ្នាក់ប្រសើរឡើងធៀបនឹងប្រទេសកម្ពុជា ។ ធនាគារពិភពលោក និង សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ជាសមាជិករបស់ក្រុមធនាគារពិភពលោក ដែលផ្តោតលើការអភិវឌ្ឍន៍វិស័យឯកជន និងធ្វើការជាមួយរដ្ឋាភិបាលដើម្បីកែលំអបរិយាកាសអាជីវកម្ម ។

លោក **ជីម៉ៅ ហ្វាន** (Qimiao Fan) ដែលជានាយកគ្រប់គ្រង ធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា "ការវាយតម្លៃបរិយាកាសវិនិយោគលើកទី ២ ដែលចេញផ្សាយនៅក្នុងឆ្នាំ២០០៩ ដោយ ធនាគារពិភពលោក និង សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានកំណត់នូវអាទិភាពកំណែទំរង់ ដែលនឹងជួយកែលំអបរិយាកាសអាជីវកម្មយ៉ាងច្រើន តាមរយៈការជួយរក្សាវិនិយោគិនដែលមានស្រាប់ និងទាក់ទាញវិនិយោគិនថ្មីៗ ។ ប្រការនេះនឹងធ្វើឱ្យប្រទេសកម្ពុជា ស្ថិតក្នុងជំហរដ៏ប្រសើរមួយ ដើម្បីទទួលបាននូវប្រយោជន៍ពីការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក ព្រមទាំងជួយអភិវឌ្ឍក្រុមហ៊ុនតូចៗរបស់ខ្លួន និងបង្កើតការងារ ។ "

តំណាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិប្រចាំប្រទេសកម្ពុជា លោកស្រី **ជូលា ប្រ៊ិកឃែល** (Julia Brickell) បានធ្វើការកត់សំគាល់ថា ប្រទេសកម្ពុជាកំពុងខិតខំប្រឹងប្រែង ដើម្បីកែលម្អទិដ្ឋភាពនៃបរិយាកាសអាជីវកម្ម ។ លោកស្រី **ប្រ៊ិកឃែល** (Brickell) បានមានប្រសាសន៍ថា " សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដោយមានការគាំទ្រពីសហគមន៍អឺរ៉ុប និងម្ចាស់ជំនួយដទៃទៀត កំពុងជួយដល់រដ្ឋាភិបាលដើម្បីធ្វើការកែលំអ ការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ដែលនឹងដោះស្រាយវិវាទពាណិជ្ជកម្មរហ័សជាង និងក្នុងតម្លៃទាបជាងមួយជំនួសឱ្យតុលាការ ។ យើងកំពុងជួយធ្វើការជ្រើសរើសមជ្ឈត្តករ និងកំពុងរៀបចំកម្មវិធីមួយសំរាប់បណ្តុះបណ្តាលពួកគេដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម ។ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមានប្រសិទ្ធិភាពមានសារៈសំខាន់ណាស់ ក្នុងការជួយដល់អាជីវកម្មឱ្យអនុវត្តកិច្ចសន្យា ដោយប្រើមធ្យោបាយ ដែលចំណាយពេល និងប្រាក់តិចជាងពេលបច្ចុប្បន្ន ។ "

ជាលទ្ធផលនៃកំណែទំរង់របស់ខ្លួន ប្រទេសឥណ្ឌូនេស៊ី ដែលជាអ្នកធ្វើកំណែទម្រង់សកម្មជាងគេនៅក្នុងតំបន់ បានឈានដល់លំដាប់ទី១២២ ពី១២៩ ក្នុងចំណាត់ថ្នាក់ការធ្វើអាជីវកម្មពិភពលោក។ ប្រទេសឥណ្ឌូនេស៊ីបាន កាត់បន្ថយពេលវេលា ក្នុងការចាប់ផ្តើមធ្វើអាជីវកម្មមកត្រឹម ១៦ថ្ងៃ និងពេលវេលាផ្ទេរទ្រព្យមកត្រឹម១៧ថ្ងៃ។ ប្រទេសនេះក៏បានពង្រឹងនូវ ការទាមទារឱ្យមានការបង្ហាញជាសាធារណៈ អំពីប្រតិបត្តិការភាគីពាក់ព័ន្ធ ដើម្បីការពារ វិនិយោគិន។

ប្រទេសសឹង្ហបូរី ដែលជាប្រទេសធ្វើការកែទំរង់យ៉ាងទៀងទាត់ ជាប់ចំណាត់ថ្នាក់ខ្ពស់ជាងគេក្នុងការសំរួលដល់ការធ្វើ អាជីវកម្មក្នុងរយៈពេលបួនឆ្នាំជាប់គ្នា ហើយប្រទេសញូវែលហ្សេឡង់ជាប់ចំណាត់ថ្នាក់បន្ទាប់។ ប្រទេសសឹង្ហបូរី បានដាក់ចេញឱ្យអនុវត្តសេវាជួយសំរួលការចាប់ផ្តើមអាជីវកម្ម លិខិតអនុញ្ញាតិសាងសង់ និងការផ្ទេរទ្រព្យ តាមរយៈអ៊ិនធើណេត និងប្រព័ន្ធកុំព្យូទ័រ។

កំណែទំរង់ផ្សេងៗបានកើតឡើងនៅទូទាំងតំបន់។ ប្រទេសថៃបានជួយសំរួលដល់ការចាប់ផ្តើមអាជីវកម្ម ហើយទទួល បានចំណាត់ថ្នាក់ ទី១២ នៅក្នុងចំណាត់ថ្នាក់លើការសំរួលដល់ការធ្វើអាជីវកម្មពិភពលោក។ ប្រទេសចិនបានជួយ សំរួលដល់ក្រុមហ៊ុនក្នុងស្រុកក្នុងការធ្វើពាណិជ្ជកម្ម ដោយបន្ធូរបន្ថយបទបញ្ញត្តិស្តីពីឥណទានពាណិជ្ជកម្ម។ ប្រទេស ហ្វីលីពីនបានដាក់ឱ្យអនុវត្តនូវបទបញ្ញត្តិស្តីពីក្ស័យធនថ្មី ដើម្បីធ្វើឱ្យមានភាពងាយស្រួលក្នុងការទទួលស្គាល់ក្រុមហ៊ុន នានា។ សេដ្ឋកិច្ចនានាក្នុង តំបន់ប៉ាស៊ីហ្វិកក៏នឹងបន្តបង្កើនល្បឿនកំណែទំរង់ផងដែរ។ ប្រទេស ហ្វីជី (Fiji) ប៉ាពូញូវហ្គីនេ (Papua New Guinea) សាម៉ៅ (Samao) តុងហ្គា (Tonga) និងវ៉ានូទូ (Vanuatu) បានកែទំរង់វិស័យមួយចំនួនរួមមាន ការចាប់ផ្តើមអាជីវកម្ម ការទទួលបានឥណទាន ការបង់ពន្ធ និងការអនុវត្ត កិច្ចសន្យា។

របាយការណ៍ *ការធ្វើអាជីវកម្ម* ចាត់ចំណាត់ថ្នាក់ប្រទេសទាំង ១៨៣ យោងតាមសូចនករបទបញ្ញត្តិចំនួន១០ ដែលការចាត់ចំណាត់ថ្នាក់នេះវិភាគលើរយៈពេល និងចំណាយដែលក្រុមហ៊ុនក្នុងស្រុកត្រូវចំណាយ ដើម្បីធ្វើស្របនឹង បញ្ញត្តិពាណិជ្ជកម្ម ដូចជា ការចាប់ផ្តើម និងប្រតិបត្តិការអាជីវកម្ម ការធ្វើអាជីវកម្មឆ្លងកាត់ព្រំដែន ការបង់ពន្ធ និងការបិទអាជីវកម្ម។ របាយការណ៍ *ការធ្វើអាជីវកម្ម* មិនវាស់វែងរាល់ទិដ្ឋភាពនៃបរិយាកាសអាជីវកម្ម ដែលទាក់ទងនឹងក្រុមហ៊ុន និងវិនិយោគិនឡើយ។ ឧទាហរណ៍ៈ ការធ្វើអាជីវកម្មមិនវាស់វែងអំពីសន្តិសុខ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច អំពើពុករលួយ កំរិតជំនាញ ឬក៏ កំលាំងរបស់ប្រព័ន្ធហិរញ្ញវត្ថុឡើយ។

## **អំពីក្រុមធនាគារពិភពលោក**

ក្រុមធនាគារពិភពលោកគឺជាប្រភពផ្តល់មូលនិធិ និងចំណេះដឹងដ៏ធំជាងគេនៅក្នុងពិភពលោកសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍នានា។ ក្រុមធនាគារពិភពលោករួមមានស្ថាប័នរួមគ្នាធំៗចំនួនប្រាំ: ធនាគារអន្តរជាតិសំរាប់ការអភិវឌ្ឍន៍ និងការកសាងឡើងវិញ(IBRD) សមាគមសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ(IDA) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) ទីភ្នាក់ងារធានាការវិនិយោគពហុភាគី(MIGA) និងមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ(ICSID)។ ស្ថាប័ននីមួយៗដើរតួនាទីដាច់ដោយឡែកពីគ្នានៅក្នុងបេសកកម្មដើម្បីប្រយុទ្ធនឹងភាពក្រីក្រ និងកែលំអរជីវភាពរស់នៅរបស់ប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ សំរាប់ពត៌មានបន្ថែម សូមបើកគេហទំព័រ www.worldbank.org, www.miga.org និងwww.ifc.org

សំរាប់ពត៌មានបន្ថែមអំពីរបាយការណ៍ការធ្វើអាជីវកម្ម សូមបើកគេហទំព័រ: www.doingbusiness.org

**សំរាប់ពត៌មានបន្ថែមអំពីរបាយការណ៍ការធ្វើអាជីវកម្មឆ្នាំ២០១០ សូមទំនាក់ទំនង:**


Nadine Ghannam +1 (202) 473-3011
អាស័យដ្ឋានអ៊ីម៉េល:nsghannam@ifc.org

Rebecca Ong +1 (202) 458-0434
អាស័យដ្ឋានអ៊ីម៉េល:rong@worldbank.org


**ពត៌មានសំរាប់ចំងល់ផ្សេងៗនៅក្នុងតំបន់ស្តីពីការធ្វើអាជីវកម្មឆ្នាំ២០១០:**

**តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក**


Hannfried von Hindenburg +1 (202) 460-7717
អាស័យដ្ឋានអ៊ីម៉េល:hvonhindenburg@ifc.org

Mohamad Al Arief +1 (202) 458-5964
អាស័យដ្ឋានអ៊ីម៉េល:malarief@worldbank.org